ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

លេខ:.......[illegible]

# សេចក្តីជូនដំណឹង

## ស្តីពីការប្រឡងជ្រើសរើសសិស្ស-និស្សិត ឱ្យចូលបម្រើការងារជាមន្ត្រីរាជការ ក្នុងក្របខ័ណ្ឌក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ សម្រាប់ឆ្នាំ ២០១៤

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សូមប្រកាសជូនដំណឹងដល់សិស្ស និស្សិត និងជនពិការ ទាំងពីរភេទ ដែលបានបញ្ចប់ការសិក្សាពីមហាវិទ្យាល័យ ពីវិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈនានាឱ្យបានជ្រាបថា ៖ ផ្អែកតាមលិខិតលេខ ២២២៥ មស.ក្រខ ចុះថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៣ របស់ក្រសួងមុខងារសាធារណៈ ស្តីពីផែនការក្របខ័ណ្ឌរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សម្រាប់ឆ្នាំ ២០១៤ ក្រសួងនឹងបើកការប្រឡងជ្រើសរើសឲ្យចូលបម្រើការងារក្នុងក្របខ័ណ្ឌតាមចំនួន និងលក្ខខណ្ឌដូចខាងក្រោម ៖

**១. ថ្នាក់កណ្តាល ៖**

ចំនួនជ្រើសរើស **សរុប ៣៨ កន្លែង** ដោយចែកចេញតាមមុខជំនាញ និងឯកទេស ដូចខាងក្រោម ៖

| លរ | មុខជំនាញ ឯកទេស | ចំនួនជ្រើសរើស | ក្របខ័ណ្ឌជ្រើសរើស |
|---|---|---|---|
| ១ | បុរាណវិទ្យា | ៣ | **ក** |
| ២ | ស្ថាបត្យកម្ម | ២ | **ក** |
| ៣ | នាដសាស្ត្រ | ៧ | **ក / ខ** |
| ៤ | សូនរូប | ១ | **ក / ខ** |
| ៥ | ព័ត៌មានវិទ្យា | ៧ | **ក** |
| ៦ | គណនេយ្យ | ២ | **ក** |
| ៧ | នីតិសាស្ត្រ | ៤ | **ក** |
| ៨ | ភាសាអង់គ្លេស | ៥ | **ក** |



ទូរស័ព្ទ / ទូរសារ : 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

| ល.រ | មុខជំនាញ ឯកទេស | ចំនួនជ្រើសរើស | ក្របខ័ណ្ឌជ្រើសរើស |
|---|---|---|---|
| ៩ | វិទ្យាសាស្ត្រអប់រំ | ១ | ក |
| ១០ | វិស្វកម្ម | ១ | ក |
| ១១ | អគ្គិសនី | ១ | ក |
| **សរុប** | | **៣៨** | |

## ២. ថ្នាក់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត ៖

ចំនួនជ្រើសរើស **សរុប ៤១ កន្លែង** ដោយចែកចេញដូចខាងក្រោម ៖

**១.មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ ៖**

- ចំនួនជ្រើសរើស ០៦ កន្លែង ក្របខ័ណ្ឌ (ក / ខ) ដែលមានសញ្ញាបត្រ គណនេយ្យ, ធនាគារ និងហិរញ្ញវត្ថុ, គ្រប់គ្រងរដ្ឋបាល, នាដសាស្ត្រ (តែងនិពន្ធរឿង / ល្ខោននិយាយ / ល្ខោនយីកេ), សូនរូប, ត្បូរតន្ត្រី (តន្ត្រីបុរាណ)។

**២.មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តប៉ៃលិន ៖**

- ចំនួនជ្រើសរើស ០១ កន្លែង ក្របខ័ណ្ឌ (ក / ខ) ដែលមានសញ្ញាបត្រ សូនរូប, នាដសាស្ត្រ, បុរាណវិទ្យា។

**៣.មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកណ្ដាល ៖**

- ចំនួនជ្រើសរើស ០២ កន្លែង ក្របខ័ណ្ឌ (ក / ខ) ដែលមានសញ្ញាបត្រ បុរាណវិទ្យា, សូនរូប, នាដសាស្ត្រ (របាំបុរាណ / របាំប្រពៃណី)។

**៤.មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តតាកែវ ៖**

- ចំនួនជ្រើសរើស ០១ កន្លែង ក្របខ័ណ្ឌ (ក / ខ / គ) ដែលមានសញ្ញាបត្រ គ្រប់គ្រងទូទៅ, សូនរូប (វិចិត្រកម្ម), មធ្យមសិក្សាទុតិយភូមិ។

**៥.មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកំពង់ស្ពឺ ៖**

- ចំនួនជ្រើសរើស ០៣ កន្លែង ក្របខ័ណ្ឌ (ក / ខ / គ) ដែលមានសញ្ញាបត្រ ព័ត៌មានវិទ្យា, គ្រប់គ្រង, ភាសាអង់គ្លេស, ត្បូរតន្ត្រី, នាដសាស្ត្រ, មធ្យមសិក្សាទុតិយភូមិ។

**៦.មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកំពត ៖**

- ចំនួនជ្រើសរើស ០២ កន្លែង ក្របខ័ណ្ឌ (ក / ខ) ដែលមានសញ្ញាបត្រ ព័ត៌មានវិទ្យា, គ្រប់គ្រង។

**៧.មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកោះកុង ៖**

- ចំនួនជ្រើសរើស ០២ កន្លែង ក្របខ័ណ្ឌ (ក / ខ / គ) ដែលមានសញ្ញាបត្រ គ្រប់គ្រង, មធ្យមសិក្សាទុតិយភូមិ។

៨.មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តព្រៃវែង ៖

- ចំនួនជ្រើសរើស ០៤ កន្លែង ក្របខ័ណ្ឌ (ក / ខ) ដែលមានសញ្ញាបត្រ រដ្ឋបាលទូទៅ, បុរាណវិទ្យា, នាដសាស្ត្រ, សូនរូប។

៩.មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកំពង់ចាម ៖

- ចំនួនជ្រើសរើស ០១ កន្លែង ក្របខ័ណ្ឌ (ក / ខ / គ) ដែលមានសញ្ញាបត្រ សេដ្ឋកិច្ច និងគ្រប់គ្រង, ភាសាអង់គ្លេស, ព័ត៌មានវិទ្យា, មធ្យមសិក្សាទុតិយភូមិ។

១០.មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកំពង់ឆ្នាំង៖

- ចំនួនជ្រើសរើស ០២ កន្លែង ក្របខ័ណ្ឌ (ក / ខ / គ) ដែលមានសញ្ញាបត្រ បុរាណវិទ្យា, មធ្យមសិក្សាទុតិយភូមិ។

១១.មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តពោធិ៍សាត់ ៖

- ចំនួនជ្រើសរើស ០២ កន្លែង ក្របខ័ណ្ឌ (ក / ខ)។

១២.មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តបាត់ដំបង ៖

- ចំនួនជ្រើសរើស ០២ កន្លែង ក្របខ័ណ្ឌ (ក / ខ / គ) ដែលមានសញ្ញាបត្រ បុរាណវិទ្យា, នាដសាស្ត្រ, សូនរូប, មធ្យមសិក្សាទុតិយភូមិ។

១៣.មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តបន្ទាយមានជ័យ ៖

- ចំនួនជ្រើសរើស ០២ កន្លែង ក្របខ័ណ្ឌ (ក / ខ / គ) ដែលមានសញ្ញាបត្រ បុរាណវិទ្យា, នាដសាស្ត្រ, មធ្យមសិក្សាទុតិយភូមិ។

១៤.មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តសៀមរាប ៖

- ចំនួនជ្រើសរើស ០២ កន្លែង ក្របខ័ណ្ឌ (ក / ខ) ដែលមានសញ្ញាបត្រ ព័ត៌មានវិទ្យា, គណនេយ្យ, នាដសាស្ត្រ (សិល្បៈរបាំ)។

១៥.មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តកំពង់ធំ ៖

- ចំនួនជ្រើសរើស ០២ កន្លែង ក្របខ័ណ្ឌ (ក / ខ) ដែលមានសញ្ញាបត្រ គណនេយ្យ, ធនាគារ និងហិរញ្ញវត្ថុ, គ្រប់គ្រង, បុរាណវិទ្យា។

១៦.មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តក្រចេះ ៖

- ចំនួនជ្រើសរើស ០១ កន្លែង ក្របខ័ណ្ឌ (ក / ខ) ដែលមានសញ្ញាបត្រ សូនរូប, នាដសាស្ត្រ។

១៧.មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តស្ទឹងត្រែង ៖

- ចំនួនជ្រើសរើស ០៤ កន្លែង ក្របខ័ណ្ឌ (ក / ខ / គ)។

១៨.មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ ខេត្តព្រះវិហារ ៖

- ចំនួនជ្រើសរើស ០២ កន្លែង ក្របខ័ណ្ឌ (ក / ខ / គ) ដែលមានសញ្ញាបត្រ គណនេយ្យ, មធ្យមសិក្សាទុតិយភូមិ។

### ៣. លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើស ៖

- សម្រាប់ប្រភេទ **ក្របខ័ណ្ឌ "ក"** និស្សិតដែលមានកម្រិតបណ្ដុះបណ្ដាលមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅ ដែលមានអាយុមិនឱ្យលើសពី **៣០ឆ្នាំ** គិតមកដល់ថ្ងៃប្រឡង។

- សម្រាប់ប្រភេទ **ក្របខ័ណ្ឌ "ខ"** សិស្ស និស្សិតដែលមានកម្រិតបណ្ដុះបណ្ដាលមានសញ្ញាបត្រស្នាតកបត្រសិល្បៈ បរិញ្ញាបត្ររង ឬសញ្ញាបត្រសមមូល ដែលមានអាយុមិនឱ្យលើសពី **២៨ឆ្នាំ** គិតមកដល់ថ្ងៃប្រឡង។

- សម្រាប់ប្រភេទ **ក្របខ័ណ្ឌ "គ"** សិស្ស និស្សិតដែលមានកម្រិតបណ្ដុះបណ្ដាលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឡើង ឬសញ្ញាបត្រសមមូល ដែលមានអាយុចាប់ពី **១៨ឆ្នាំ** និងមិនឱ្យលើសពី **២៥ ឆ្នាំ** គិតមកដល់ថ្ងៃប្រឡង។

- *ចំពោះបេក្ខជនដែលដាក់ពាក្យសុំសិទ្ធប្រឡងចូលបម្រើការងារនៅក្នុងក្របខ័ណ្ឌមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត ត្រូវមានអាសយដ្ឋានច្បាស់លាស់រស់នៅក្នុងបណ្ដាឃុំ ស្រុក ខេត្ត ដែលសាមីខ្លួនដាក់ពាក្យសុំប្រឡងនោះផ្ទាល់ ហើយអាចដាក់ពាក្យសុំសិទ្ធិប្រឡងនៅមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈសាមី ឬដាក់នៅទីស្ដីការក្រសួងក៏បាន។*

- *ចំពោះបេក្ខជនជាជនពិការ ជនជាតិភាគតិចនៅដាច់ស្រយាល ទាំងពីរភេទ ដែលមានសមត្ថភាពសមស្រប ត្រូវបានលើកទឹកចិត្ត។*

### ៤. កាលបរិច្ឆេទប្រឡង ៖

- វិញ្ញាសាសរសេរ ***នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤***

### ៥. អំពីវិញ្ញាសាប្រឡង ៖

កម្រិតឧត្ដម ក្របខ័ណ្ឌ (ក) និងមធ្យម ក្របខ័ណ្ឌ (ខ) ៖

- ជំនាញ និងឯកទេស រយៈពេល ២ ម៉ោង
- ភាសាអង់គ្លេស (ដែលខ្លឹមសារមានទំនាក់ទំនងនឹងវិស័យវប្បធម៌) រយៈពេល ២ ម៉ោង

កំរិតបឋម ក្របខ័ណ្ឌ (គ) ៖ *(សម្រាប់បេក្ខជនបម្រើការងារនៅមន្ទីររាជធានី-ខេត្ត)*

- វប្បធម៌ទូទៅ រយៈពេល ២ ម៉ោង

### ៦. កាលបរិច្ឆេទទទួលពាក្យ និងឈប់ទទួលពាក្យ ៖

- កាលបរិច្ឆេទទទួលពាក្យចុះឈ្មោះប្រឡង ចាប់ពីថ្ងៃផ្សាយដំណឹងនេះតទៅ **នៅនាយកដ្ឋានបុគ្គលិក ការិយាល័យរៀបចំ និងក្របខ័ណ្ឌ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាន់ទី ៣ រៀងរាល់ម៉ោងធ្វើការ។**

- កាលបរិច្ឆេទឈប់ទទួលពាក្យ **នៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ២០១៤ វេលាម៉ោង ១៧:០០ ល្ងាច។**

៧. **<u>សំណុំលិខិតសុំចុះឈ្មោះប្រឡង ៖</u>**

- ពាក្យសុំចុះឈ្មោះប្រឡងមានបិទតែម (៦០០៖០០) ចំនួន ០១ ច្បាប់
- សេចក្តីចម្លងសញ្ញាបត្រ "ដែលមានបញ្ជាក់ជាផ្លូវការ ពីសាលារាជធានី-ខេត្ត" ចំនួន ០១ ច្បាប់
- សេចក្តីចម្លងសំបុត្រកំណើត "ជាផ្លូវការ" ចំនួន ០១ ច្បាប់
- ជីវប្រវត្តិសង្ខេបមានបិទរូបថត (៤ x ៦) ចំនួន ០១ ច្បាប់
- សលាកបត្រឯកត្តជន មានបិទរូបថត (៤ x ៦) ចំនួន ០១ ច្បាប់
- កិច្ចសន្យាបម្រើការងារក្រសួង ចំនួន ០១ ច្បាប់
- បង្កាន់ដៃបង់សិទ្ធិប្រឡង ចំនួន ០១ ច្បាប់
- រូបថតថ្មី ៤ x ៦ "ថតចំពីមុខ" ចំនួន ០៣ សន្លឹក
- លិខិតបញ្ជាក់កិរិយាមាយាទ (ដែលចេញដោយអាជ្ញាធរមូលដ្ឋាន) "ក្រោយពេលប្រឡងជាប់" ចំនួន ០១ ច្បាប់
- លិខិតបញ្ជាក់សុខភាព "ក្រោយពេលប្រឡងជាប់" ចំនួន ០១ ច្បាប់

**<u>កំណត់សំគាល់:</u>**

- បេក្ខជនត្រូវសរសេរបំពេញពាក្យសុំប្រឡង ចុះហត្ថលេខា និងមកដាក់ពាក្យដោយផ្ទាល់ខ្លួន។
- កន្លែងទំនាក់ទំនង និងដាក់ពាក្យប្រឡង **នៅនាយកដ្ឋានបុគ្គលិក ការិយាល័យបៀវត្សរ៍ និងក្របខ័ណ្ឌ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាន់ទី ៣ រៀងរាល់ម៉ោងធ្វើការ។**

រាជធានីភ្នំពេញ,ថ្ងៃទី ០២ ខែមករា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

ភឿង_សកុណា

**បម្លងជូន ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  <u>"ដើម្បីជូនជ្រាបជាព័ត៌មាន"</u>
- គ្រប់ក្រសួង ស្ថាប័ន
- ...ស្សន៍ជាតិកម្ពុជា "មេត្តាជួយផ្សព្វផ្សាយ"
- ...ស្សន៍អាស៊ីអាគ្នេយ៍ "មេត្តាជួយផ្សព្វផ្សាយ"
- ...ស្សន៍បាយ័ន "មេត្តាជួយផ្សព្វផ្សាយ"
- ...ស្សន៍អប្សរា "មេត្តាជួយផ្សព្វផ្សាយ"
- ...ក្រសួង
និងគ្រប់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី-ខេត្ត
  <u>"ដើម្បីផ្សព្វផ្សាយ"</u>
- ឯកសារ-កាលប្បវត្តិ



5 /5